# កំណាព្យ

## ទូលត្រៃចីវរ

បទបង្សាវត្ត

ពៅស្រីទូលត្រៃចីវរនៅវត្ត ចិត្តល្អប្រតិព័ទ្ធចំពោះព្រះ
ខំបដិបត្តិធម៌ឱ្យចាំចេះ ទុកជាចំណេះជាក្បួនប្រមុខ។
កាយនិងវាចាក្នុងសីលគ្មានខុស កុំឱ្យមានទុក្ខប្រចាំជីវិត
លើកដៃទាំងទ្វេសុំផ្សងតែព្រឹទ្ធិ[1] សុំសីលមានឫទ្ធិសំរាប់សត្វលោក។
ទូលត្រៃទាំងញញឹមឱ្យប្តីថត ចិត្តមានបំណងស្វែងរកស្រឡាញ់
ពៅអើយអូនស្រីចិត្តបងគ្មានក្នាញ់[2] ញញឹមក្រមាច់[3]ប្តីសុំសារភាព។
សុំឱ្យស្នេហ៍យើងឥតមារបៀតបៀន ចូលមកបំពានដែនសុខស្នោះត្រង់
ព្រះត្រៃចីវរចងចិត្តតម្រង់ ឱ្យចេះតម្កល់សាមគ្គីគ្រប់កាល។



ប្រើវចនានុក្រមខ្មែររបស់ពុទ្ធសាសនបណ្ឌិត្យ

---

[1] ព្រឹទ្ធិ : សេចក្តីចំរើន។
[2] គ្មានក្នាញ់ : គ្មានទាស់ចិត្ត។
[3] ក្រមាច់ : គុ. ដែលចេះកំប្លែងដោយវាចា ឬ អវៈយវៈ។